# មន្ទីរព្យាបាលវិបត្តិផ្លូវចិត្តដំបន់ San Joaquin
## របៀបបំណោះស្រាយបញ្ហា
## ការិយាល័យចាត់ការឲ្យមានគុណភាព និងការធ្វើឲ្យប្រសើរឡើង

1212 N. California Street
Stockton, CA 95202

បើអ្នកទទួលការព្យាបាលនៅមន្ទីរព្យាបាលវិបត្តិដំបន់ San Joaquin និងមានមេធាវីខាល់ហើយមានបំណងចង់ប្តឹងសារទុក្ខ,តវ៉ាតាមធម្មតា,ឬតវ៉ាឲ្យបានរួសរាន់ (មើលអត្ថន័យខាងក្រោម), អ្នកអាចបំពេញពាក្យបណ្តឹងសំរាប់គោលបំណងនោះ,ប្រាប់បុគ្គលិកធ្វើការណាម្នាក់,សរសេរសំបុត្រ,ឬទូរស័ព្ទទៅ **បំណោះស្រាយបញ្ហា**។

**បំណោះស្រាយបញ្ហា**
**លេខទូរស័ព្ទ :** (209)-468-9393
**ទូរស័ព្ទឥតគិតថ្លៃ :** (866) 468-9393
**លេខទូរសារ :** (209) 468-8485

អ្នកដែលទទួលផលពីមេធាវីខាល់អាចសុំសវនាការពីរដ្ឋ **បន្ទាប់**ពីដំណើរការតវ៉ាត្រូវបានបំពេញសព្វគ្រប់,ដោយទូរស័ព្ទទៅក្រសួងសង្គមកិច្ចរដ្ឋកាលីហ្វ័រញ៉ាលេខ (800) 952-5253, ឬ TDD (សំរាប់អ្នកថ្លង់) (800) 952-8349, ឬសរសេរទៅ :

State Hearing Division,
California Department of Social Services,
PO Box 944243, Mail Station 19-37,
Sacramento, CA 94244-2430.

អ្នកទទួលការព្យាបាលដែលមាន ឬក៏គ្មានមេធាវីខាល់ កំពុងទទួលបានការព្យាបាលពីមន្ទីរព្យាបាលវិបត្តិផ្លូវចិត្តដំបន់ San Joaquin អាចឲ្យយើងដឹងពីការឲ្យយោបល់,ការចាប់អារម្មណ៍,ឬសេចក្តីសរសើរ។ អ្នកអាចបំពេញក្រដាស់ស្នាមមួយខាងក្រោម,ប្រាប់បុគ្គលិកធ្វើការណាម្នាក់,សរសេរសំបុត្រ,ឬទូរស័ព្ទទៅ **បំណោះស្រាយបញ្ហា**។

១. **ចំណាប់អារម្មណ៍_** បញ្ហារឿងរ៉ាវណាមួយដែលអ្នកមកព្យាបាល មានបំណងចង់យកមកពិភាក្សាជាមួយបុគ្គលិកធ្វើការ ឬអ្នកចាត់ការ។
២. **សារទុក្ខ_** ការសំដែងមនោសច្ចេតនានៃការមិនពេញចិត្ត អំពីរឿងរ៉ាវណាមួយ ក្រៅពីរឿងរាយការណ៍ដោយ**តវ៉ា**ដូចមានអត្ថន័យខាងក្រោម។
៣. **ការតវ៉ា_** សំណូមសំរាប់ការសើរើនៃការ**សំរេច**ចិត្តចុងក្រោយ ត្រូវបដិសេធទាំងស្រុង ឬក្នុងផ្នែកខ្លះ សំណូមរបស់អ្នកដែលទទួលផល សំរាប់ចំណាយជាពិសេសទៅលើការព្យាបាលវិបត្តិ ឬសំរាប់សើរើនៃការសំរេចចិត្តចុងក្រោយ ថាមិនត្រូវបានទទួលព្យាបាលជាចាំបាច់តាមលក្ខណៈវិនិច្ឆ័យ និងមិនមានសិទ្ធិអាចទទួលនូវការព្យាបាលវិបត្តិផ្នែកផ្លូវចិត្តជាពិសេសណាមួយទេ។
៤. **ការសំរេច_** ការសំរេចកើតមានឡើងនៅពេលដែលអ្នកផ្តល់ការព្យាបាល សំរេចចិត្តយ៉ាងតិចមួយនៃផ្នែកខាងក្រោមនេះ :
- បដិសេធ ឬកែប្រែមិនព្រមអនុញ្ញាតិចេញថ្លៃឲ្យព្យាបាលវិបត្តិ MHP តាមសំណូម,រួមទាំងបែប ឬកំរិតនៃការព្យាបាល
- បន្ថយ,បញ្ឈប់,ឬបញ្ចប់ការអនុញ្ញាតិឲ្យព្យាបាលដែលមានចាប់តាំងពីមុនមក
- បដិសេធបង់ថ្លៃសំរាប់ការព្យាបាលពីមុនដែលធ្វើ ឬក៏បញ្ជូនមកតាមប្រៃសណីយ ឬបង់ថ្លៃជាមុនយោលទៅតាមការសំរេចចិត្តថា ការព្យាបាលដែលមិនត្រូវការចាំបាច់ ឬបើមិនដូច្នោះទេ គឺជាការព្យាបាលដោយមិនបានគ្របដណ្តប់ដោយកិច្ចសន្យា។
- ខកខានមិនបានផ្តល់ការព្យាបាល តាមកំណត់ពេលវេលា។
- ខកខានសំរេច ក្នុងពេលការសំរេចចុងក្រោយបង្អស់នៃសារទុក្ខធម្មតា,បំណោះស្រាយនៃការតវ៉ាតាមធម្មតា,ឬបំណោះស្រាយនៃការតវ៉ាធ្វើឲ្យបានរួសរាន់។
- បដិសេធការស្នើសុំចង់បានជួយបង់សងថ្លៃ រួមទាំងការជួយបង់ថ្លៃមួយចំណែក និងការជួយសងថ្លៃអ្វីៗដ៏ទៃទៀត។

៥. **ការតវ៉ាធ្វើឲ្យបានរួសរាន់_** ការតវ៉ាធ្វើឲ្យបានរួសរាន់អាចនឹងដាក់ពាក្យតវ៉ា បើជីវិតអ្នកមកព្យាបាល,សុខភាព ឬសមត្ថភាពសំរេច,ថែទាំ, ឬទទួលមុខការឡើងវិញ ដែលប្រកបដោយគ្រោះថ្នាក់យ៉ាងខ្ពស់បំផុត។ ដូចជារបៀបដាក់ពាក្យសុំ**៣**យ៉ាងដូចខាងលើ លើកលែងតែការសំរេចចិត្តនឹងត្រូវធ្វើក្នុងរវាង៧២ម៉ោង។

- អ្នកនឹងអាចរកឃើញក្រដាស់បំពេញ នៅតាមប្រអប់ផ្តល់យោបល់ គេមានចារខ្ទងសំបុត្រទៅមន្ទីរព្យាបាលវិបត្តិផ្លូវចិត្តដំបន់ San Joaquin ការគ្រប់គ្រងដែលមានគុណភាព និងការធ្វើឲ្យប្រសើរឡើង, ឬ
- អ្នកអាចប្រើក្រដាស់សំបុត្រណាមួយក៏បាន។
- បើអ្នកចូលចិត្ត អ្នកអាចសរសេរមកយើងតាមអស័យដ្ឋានដែលមាននៅខាងលើស្រាប់, ឬ
- បើអ្នកចូលចិត្ត អ្នកអាចសុំឲ្យបុគ្គលិកធ្វើការណាម្នាក់ នៅមន្ទីរព្យាបាលវិបត្តិផ្លូវចិត្តដំបន់ San Joaquin ជួយបំពេញក្រដាស់ឲ្យអ្នក។

**មានការបកប្រែភាសាដោយឥតគិតថ្លៃសំរាប់អ្នកមកព្យាបាលនៅ SJCBHS.**